# សៀវភៅបណ្តុំបច្ចេកទេស
# ប្រពលវប្បកម្មដំណាំស្រូវ



នាយកដ្ឋានដំណាំស្រូវ នៃអគ្គនាយកដ្ឋានកសិកម្ម

ខែ មីនា ឆ្នាំ ២០១១

## អ្នករៀបរៀង

លោក **ទិន ឆាយ** នាយកដ្ឋានដំណាំស្រូវ

បណ្ឌិត **ឃុន លាងឆោក** នាយកដ្ឋានដំណាំស្រូវ

លោក **គង់ តា** នាយកដ្ឋានដំណាំស្រូវ

លោក **ជុំ ជ័យធីរិទ្ធ** នាយកដ្ឋានដំណាំស្រូវ

លោក **ឃៀង សេនា** នាយកដ្ឋានដំណាំស្រូវ

## អ្នកផ្តល់យោបល់កែសម្រួល

១. ឯកឧត្តម **តេង ឡៅ** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២. ឯកឧត្តម **អ៊ិត ណូឌី** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៣. ឯកឧត្តម **សុ ខនឫទ្ធីគុណា** អគ្គនាយកដ្ឋានកសិកម្ម

៤. លោក **ប៉ែន ចុន** អគ្គនាយកដ្ឋានកសិកម្ម

៥. លោក **ម៉ាក់ សឿន** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៦. លោក **ជួន សុផល** សាកលវិទ្យាល័យភូមិន្ទកសិកម្ម

៧. លោក **អ៊ឹម គីរុណា** នាយកដ្ឋានដំណាំស្រូវ

៨. លោក **ធី ចាន់ណា** វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

៩. លោក **សុខគុន សុគាំគ្រូ** សាលាជាតិកសិកម្មព្រែកលៀប

១០. លោក **សយ សេង** អង្គការ FAO

១១. លោក **លុយ ពិសិទ្ធ** អង្គការ Oxfam

១២. លោកស្រី **ពាន សុខា** អង្គការសេដាក

១៣. លោក **ពុ សុវណ្ណ** អង្គការស្រែខ្មែរ

១៤. លោក **និន ចរិយា** គម្រោង CAVAC

១៥. លោក **ផាន ឆុច** រេចនាក្រាហ្វិច នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

១៦. តំណាងមន្ទីរកសិកម្មខេត្តចំនួន ១៣: ព្រៃវែង ស្វាយរៀង តាកែវ កំពត កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម និងខេត្តកណ្តាល ។

ឧបត្ថម្ភការបោះពុម្ពលើកទី១
ដោយអង្គការ Oxfam ខែមេសា ឆ្នាំ២០១១

# ស្រូវជាព្រះមេ

ស្រូវជាព្រះមេ ឆាំងពីបុរេ ផ្តល់ស្បៀងអាហារ
ដល់សត្វនិងមនុស្ស ឥន្ទ្រព្រហ្មទេវតា រស់មានសទ្ធារ
ពាសពេញសកល ។

ស្រូវជាវប្បធម៌ តំណាងបវរ ខ្មែរបានសំគាល់
ធ្វើបុណ្យជាលោក ច្រូតព្រះនង្គ័ល រំលឹកនឹកដល់
ស្រូវអ្នកមានគុណ ។

ស្រូវជាសេដ្ឋកិច្ច លើកស្ទួយជានិច្ច មាសប្រាក់ទ្រព្យធន
បំណុលជុនជាតិ យ៉ាងច្រើនលើកពន់ ទុកធ្វើជាទុន
កសាងជាតិខ្មែរ ។

ស្រូវជាជីវិត គ្រប់គ្នាត្រូវគិត អភិវឌ្ឍកែ
លំអពូជស្រូវ វិជ្ជាដាំថែ ញាប្រជីស្រែ
ឲ្យគង់វង្សនៅ ។

ស្រូវសុមម្បូណី គ្រប់ពាស្រមន្ត្រី ជួយដាំថែស្រូវ
បង្កើនភោគផល ច្រើនគ្រប់ជ្រុង សម្រេចទិសដៅ
អភិវឌ្ឍន៍ជាតិ ។៚

រៀបរៀងដោយ លោក ឌិន ឆាយ

## មាតិកាអត្ថបទ


អារម្ភកថា ........................................................ ០១

សេចក្ដីផ្ដើម ........................................................ ០៣

### ផ្នែកទី១៖ សង្ខេបលក្ខណៈទូទៅនៃដំណាំស្រូវ

I. បរិស្ថាន នៃដំណាំស្រូវ ........................................ ០៥

១.១ សីតុណ្ហភាព ........................................ ០៥

១.២ ពន្លឺ ........................................ ០៥

១.៣ សារធាតុចិញ្ចឹម ........................................ ០៦

១.៤ ទឹក ........................................ ០៦

II. អេកូបរិស្ថានដំណាំស្រូវនៅកម្ពុជា ........................................ ០៧

**២.១ អេកូបរិស្ថានខ្ពង់រាប** ........................................ ០៧

**២.២ អេកូបរិស្ថានទំនាបអាស្រ័យទឹកភ្លៀង** ........................................ ០៧

**២.៣ អេកូបរិស្ថានទឹកជ្រៅ** ........................................ ០៨

**២.៤ អេកូបរិស្ថានស្រែប្រាំង** ........................................ ០៨

III. ចំណាត់ថ្នាក់របស់ស្រូវ ........................................ ០៩

IV. ដំណាក់កាលលូតលាស់របស់ដំណាំស្រូវ ........................................ ១០

៤.១ វគ្គលូតលាស់ ........................................ ១០

៤.២ វគ្គបង្កើតផល ........................................ ១១

៤.៣ វគ្គទុំ ........................................ ១២

### ផ្នែកទី២៖ បច្ចេកទេសសម្រាប់ផលិតកម្មដំណាំស្រូវ

I. ការប្រើប្រាស់ពូជ និងគ្រាប់ពូជ ........................................ ១៥

១.១ ការធ្វើដំណុះសាក ........................................ ១៥

១.២ ការជ្រើសយកគ្រាប់ពេញទៅសាប ........................................ ១៦

II. **ការរៀបចំគ្រាប់ពូជ** ........................................ ១៨

III. **ការរៀបចំដីស្រែ** ........................................ ២០

IV. **ការត្រៀមថ្នាលសំណាប** ........................................ ២១

V. **វិធីសាស្រ្តដាំដុះ** ........................................ ២៣

- ៥.១ ការស្ទូង ........................................ ២៣
- ៥.២ ការដាំ ឬព្រោះ ........................................ ២៦

VI. **ការគ្រប់គ្រងជីជាតិដី** ........................................ ២៨

- ៦.១ ចំណាត់ថ្នាក់ដីសម្រាប់ដំណាំស្រូវនៅប្រទេសកម្ពុជា ........................................ ២៨
- ៦.២ ការប្រើប្រាស់ជី ........................................ ៣០

VII. **ការគ្រប់គ្រងទឹក** ........................................ ៣៤

VIII. **ការគ្រប់គ្រងសមាសភាពចង្រៃ** ........................................ ៣៦

- ៨.១. ស្មៅចង្រៃ ........................................ ៣៧
- ៨.២. ជំងឺលើដំណាំស្រូវ ........................................ ៣៩
- ៨.៣ សត្វបំផ្លាញដំណាំស្រូវសំខាន់ៗ ........................................ ៥១
  - ក. ប្រភេទសត្វចង្រៃសំខាន់ៗ និងវិធានការកំចាត់ ........................................ ៥១
  - ខ. សត្វមានប្រយោជន៍សំខាន់ៗក្នុងប្រព័ន្ធបរិស្ថានដំណាំស្រូវ ........................................ ៦១

IX. **ការប្រមូលផល និងការទុកដាក់** ........................................ ៧០

## អារម្ភកថា

**ស្រូវ** គឺជាដួងព្រលឹងនៃជនជាតិខ្មែរ ដែលបានចាក់ឫសយ៉ាងជ្រៅនៅក្នុងផ្នត់គំនិត អារម្មណ៍ និងបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងប្រពៃណី និងទំនៀមទម្លាប់របស់ប្រជាជាតិកម្ពុជាតាំងពីយូរលង់ណាស់មកហើយ។ ចំពោះប្រជាជនកម្ពុជា ស្រូវមិនត្រឹមតែជារុក្ខជាតិសាមញ្ញមួយប៉ុណ្ណោះទេ តែគឺជាដំណាំសៀងយ៉ាងសំខាន់ ជាវប្បធម៌ សាសនា និងនយោបាយ។ ប៉ិតិកភ័ណ្ឌជាសំណង់ផងសាស្ត្រនានាក្នុងតំបន់អង្គរ បានបញ្ជាក់យ៉ាងច្បាស់ថា ការឈានឡើងដល់កំពូលនៃអាណាចក្រខ្មែរនាសម័យអង្គរ គឺពិតជាមានការចូលរួមចំណែកយ៉ាងធំធេងពីដំណាំស្រូវ ទៅលើសេដ្ឋកិច្ច និងនយោបាយនាសម័យនោះ។ រហូតមកដល់បច្ចុប្បន្នខឿនសេដ្ឋកិច្ចកម្ពុជា នៅតែពឹងផ្អែកមួយភាគធំលើវិស័យកសិកម្ម ដោយមានប្រជាពលរដ្ឋប្រមាណ ៨៥ ភាគរយ រស់នៅជនបទ ហើយដែលក្នុងនោះភាគច្រើនលើសលប់ ប្រកបរបរធ្វើស្រែចំការ ។

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឆ្លាតវៃ មោះមុត ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានដាក់ចេញ និងអនុវត្តជាបន្ទាន់នូវគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍជាតិ ដោយផ្តោតលើការលើកស្ទួយវិស័យកសិកម្ម និងជនបទ សំដៅធានាស្ថេរភាពសៀងបង្កើតការងារ និងបង្កើនចំណូលប្រចាំគ្រួសារ និងធានាបាននូវអតិរេកស្រូវ បម្រើការនាំចេញទៀតផង។ កាលពីថ្ងៃ ១៧ ខែ សីហា ឆ្នាំ ២០១០ **រាជរដ្ឋាភិបាលកម្ពុជា** បានប្រកាសដាក់ឲ្យអនុវត្តនូវឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ក្នុងទិសដៅ សម្រេចឲ្យបាននូវផលិតផលស្រូវលើសប្រមាណជាង ៤ លានតោន និងមានលទ្ធភាពនាំចេញអង្ករជាផ្លូវការយ៉ាងតិច១លានតោននៅឆ្នាំ ២០១៥ ។

ដើម្បីចូលរួមចំណែកជំរុញការអនុវត្តគោលនយោបាយនេះឲ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ នាយកដ្ឋានដំណាំស្រូវនៃអគ្គនាយកដ្ឋានកសិកម្ម បានរៀបចំចងក្រងសៀវភៅ ‘ **បង្គុំបច្ចេកទេសសម្រាប់ផលិតកម្មដំណាំស្រូវ**’ នេះឡើងតាមរយៈការស្រាវជ្រាវឯកសារ និងការដកស្រង់បទពិសោធន៍ដែលបានអនុវត្តនាពេលកន្លងទៅ ក្នុងគោលបំណងជួយពង្រឹងបន្ថែមនូវចំណេះដឹងចំណេះធ្វើដល់អ្នកផ្សព្វផ្សាយ បងប្អូនកសិករ សំដៅជំរុញការបង្កើនផលិតកម្ម និងផលិតភាពដំណាំស្រូវ ។

សៀវភៅនេះ បង្ហាញនូវបង្គុំបច្ចេកទេសសំខាន់ៗ ដោយបានព្យាយាមសរសេរនូវពាក្យពេចន៍ ដើម្បីងាយស្រួលចងចាំ និងយកទៅអនុវត្ត ។ លើសពីនេះ

ទៀតនោះ កំបានលើកយកឧទាហរណ៍ជាក់ស្តែង និងដាក់រូបភាពដើម្បីបង្ហាញជូនអ្នកអានងាយយល់ និងចាប់អារម្មណ៍ ។

អគ្គនាយកដ្ឋានកសិកម្មសូមសំដែងនូវការដឹងគុណ និងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះការណែនាំចង្អុលបង្ហាញរបស់ឯកឧត្តមបណ្ឌិត **ចាន់ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងថ្នាក់ដឹកនាំទាំងអស់ដែលតែងបានដាក់ចេញនូវចក្ខុវិស័យ ដ៏ងឆ្លាយត្រឹមត្រូវ សម្រាប់ការអភិវឌ្ឍវិស័យកសិកម្មព្រមទាំងចាត់តាំងអនុវត្តការងារប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងទិសដៅជំរុញការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ របស់រាជរដ្ឋាភិបាលឲ្យទទួលបានជោគជ័យ ។

អគ្គនាយកដ្ឋានកសិកម្ម សូមថ្លែងអំណរគុណចំពោះរាល់គំនិតផ្តួចផ្តើមចងក្រងរៀបចំ របស់ក្រុមអ្នកនិពន្ធ និងការផ្តល់មតិកែលម្អទាំងអស់ពីគ្រប់ស្ថាប័នពាក់ព័ន្ធទាំងការរៀបចំតាក់តែង និងខ្លឹមសារបច្ចេកទេសដើម្បីជាផលប្រយោជន៍ដល់ខេមរបុត្រគ្រប់រូប។

អគ្គនាយកដ្ឋានកសិកម្ម មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថាសៀវភៅបង្កើបច្ចេកទេសដំណាំស្រូវនេះ នឹងផ្តល់នូវគំនិតថ្មីៗ ការអនុវត្តល្អៗនិងគោលការណ៍បច្ចេកទេសជាមូលដ្ឋានសម្រាប់ស្ថាប័នពាក់ព័ន្ធ និងកសិករយកទៅអនុវត្តក្នុងការលើកកម្ពស់ផលិតកម្មស្រូវឲ្យកាន់តែល្អប្រសើរ ក្នុងទិសដៅធានាសន្តិសុខស្បៀង និងកែច្នៃសម្រាប់ការនាំចេញដើម្បីលើកស្ទួយកំណើនសេដ្ឋកិច្ចជាតិ ដែលយើងទាំងអស់គ្នាតែងបានចាត់ទុកថា "**អង្ករជាមាសស**" ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១១

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកសិកម្ម**

**សូ_ខន់ឫទ្ធិគុណ**

## សេចក្តីផ្តើម

ស្រូវជាដំណាំស្បៀងដ៏សំខាន់សម្រាប់ប្រជាជនកម្ពុជា។ ដំណាំស្រូវត្រូវបានដាំដុះនៅប្រទេសយើងតាំងពីជាង ២០០០ឆ្នាំ មកហើយ ឬក៏យូរជាងនេះ ក្នុងករណីស្រូវចំការ។ រហូតមកដល់ ឆ្នាំ ២០១០ នេះ កម្ពុជាមានផ្ទៃដីដាំដុះស្រូវសរុបប្រមាណ ២,៧១ លានហិកតា ក្នុងនោះស្រូវវស្សាចំនួន ២,៣៣ លានហិកតា និងស្រូវប្រាំងចំនួន ០,៣៨ លានហិកតា។ នៅក្នុងប្រទេសកម្ពុជា ផ្ទៃដីស្រែទំនាបពឹងទឹកភ្លៀងមានទំហំធំជាងគេ ដែលមានប្រមាណ ៨០% នៃផ្ទៃដីស្រូវសរុប។

កសិករខ្មែរភាគច្រើន ដាំដុះស្រូវលើស្រែទំនាបពឹងទឹកភ្លៀងតាមទំលាប់ស្ទូង ដោយប្រើគ្រាប់ពូជច្រើនពី ៦០-៨០ គ.ក លើផ្ទៃដីមួយហិកតា ដែលធ្វើឲ្យគាត់ត្រូវចំណាយថវិកាច្រើនសម្រាប់ទិញគ្រាប់ពូជព្រមទាំងកម្លាំងពលកម្មដ៏ច្រើនក្នុងការរៀបចំថ្នាល ការដកសំណាប និងការដឹកជញ្ជូនសំណាបយកទៅស្ទូង។ សំណាបដែលត្រូវដកយកទៅស្ទូង ជាទូទៅមានអាយុពី ១-២ ខែ ហើយស្ទូងចាប់ពី ៥-៨ ដើម ក្នុងមួយគុម្ព ថែមទាំងស្ទូងញឹកទៀតផង (ចន្លោះគុម្ពប្រហែល ១០-១៥ ស.ម)។ ចំណែកឯការប្រើប្រាស់ជីគីមី និងថ្នាំកសិកម្ម ជាពិសេសថ្នាំសម្លាប់សត្វល្អិត ថ្នាំសម្លាប់ស្មៅជាដើម មិនទាន់សមស្របតាមបច្ចេកទេសនៅឡើយ ដែលជាហេតុធ្វើឲ្យទិន្នផលទាប ហើយការអនុវត្តខ្លះ ធ្វើឲ្យប៉ះពាល់ដល់សុខភាពមនុស្ស និងបរិស្ថានទៀតផង។

ដោយមើលឃើញនូវចំណុចខ្វះខាតទាំងនេះ ទើបក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាពិសេសដោយមានការផ្តួចផ្តើមគំនិត និងការណែនាំ ជាប្រចាំ របស់ឯកឧត្តមបណ្ឌិត **ចាន់ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងឯកសារបច្ចេកទេសស្តីពីប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ ហៅកាត់ថា ប.វ.ស (System of Rice Intensification) ដើម្បីផ្សព្វផ្សាយដល់កសិករឲ្យកាន់តែទូលំទូលាយក្នុងគោលបំណងបង្កើនផលិតភាពដំណាំស្រូវ ។ លើសពីនេះទៀត ក៏មានស្ថាប័នរដ្ឋ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើន បានសិក្សាស្រាវជ្រាវ